# សិលាចារឹក និងអក្សរថ្មរកឃើញថ្មីនៅប្រាសាទបន្ទាយប្រី

ប្រាសាទបន្ទាយប្រីមានទីតាំងនៅខាងជើងប្រាសាទព្រះខ័ន ចម្ងាយប្រហែល១៥០ម៉ែត្រ (រូបលេខ១)។ តាមទិដ្ឋភាពជាក់ស្តែង និងប្លង់របស់លោក ឡាហ្សង់ហ្គីយ៉េ ប្រាសាទនេះមានទំហំធំល្មម មានកំពែង២ជាន់ និងថែវខាងក្នុង១ជាន់ (រូបលេខ២)។ កំពែងខាងក្រៅធ្វើអំពីថ្មបាយក្រៀម រីឯកំពែងខាងក្នុងធ្វើអំពីថ្មបាយក្រៀម និងក្លោងទ្វារទាំង២ (កើត លិច) ធ្វើពីថ្មភក់ពណ៌ប្រផេះ។ នៅចន្លោះកំពែងទាំង២នេះមានកស្សិណាមួយ ជាប់អែបនិងកំពែងទី២។ នៅខាងក្នុងគឺជាថែវធ្វើពីថ្មភក់ មានក្លោងទ្វារសំខាន់៤រត់ត្រង់ផ្ចិតកណ្តាលរបស់ប្រាង្គកណ្តាល ប្រកចូលតូច៤ទៀតនៅតាមទិសរណបទាំង និងប្រកចូលតូចចន្លោះទ្វារធំនិងទ្វារតាមជ្រុងចំនួន៨ សរុបគឺមានចំនួន១៦។ នៅខាងក្នុងបង្អស់គឺជាប្រាង្គទោលនៅចំកណ្តាល មានប្លង់ជាកាកបាទ មានប្រកចូលទាំង៤ទិស។ ប្រាសាទនេះ លោក ឡាហ្សង់ហ្គីយ៉េ បានអោយលេខបញ្ជី IK. 524។[១]

ពុំមានសិលាចារឹកណាមួយបរិយាយអំពីឆ្នាំនៃការសាងសង់ប្រាសាទនេះទេ។ ប៉ុន្តែតាមរយៈរចនាសម្ព័ន្ធសំណង់ និងក្បាច់លម្អនានា បង្ហាញថាប្រាសាទនេះស្ថិតក្នុងរចនាបថបាយ័ន្ត ឬក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១គ.សដល់១២២០គ.ស)។ ទោះបីជាពុំមានសិលាចារឹកបង្ហាញពីកាលបរិច្ឆេទនៃការសាងសង់ តែគេឃើញមានសិលាចារិក១ផ្ទាំងខ្លីៗនៅលើសុំទ្វារ បង្ហាញពីការឧទ្ទិសប្រាសាទនេះដល់បុគ្គលដែលគេឱ្យតម្លៃជាទេពក្នុងប្រាសាទនេះ។ សិលាចារឹកនេះ លោកសឺដេស បានឱ្យលេខបញ្ជី K.526[២] ឋិតនៅលើសុំទ្វារខាងលិច ទ្វារខាងជើង នៃបន្ទប់ជ្រុងអាគ្នេយ៍។ សិលាចារឹកនេះមាន៤បន្ទាត់ ដែល៣បន្ទាត់ខាងលើជាឈ្មោះទេពផ្សេងៗគ្នា និងបន្ទាត់ខាងក្រោមបង្ហាញថាទីរបស់បុគ្គលដែលស្លាបនា (រូបលេខ៣)។

(១) កម្រតេង៑ ជគត ស្រីរាជឝិល្បីន្ទ្រេឝ្វរ (kaṃrateṅ jagat çrīrājaçilpindreçvara)

(២) កម្រតេង៑ជគតស្រីចន្ទ្រេឝ្វរ (kaṃrateṅ jagat çrīcāndreçvara)

(៣) កម្រតេង៑ជគតស្រីឝាន្តីឝ្វរី (kaṃrateṅ jagat çrīçantīçvarī)

---

[១] E. Lunet de Lajonquière., 1911:157

[២] George Cœdès, 1951:116

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

(៤) តិវ្រះអំតេងរាជសិល្បិស្ថាបនា (ti vraḥ aṃteṅ rājaçilpi sthāpanā)

បន្ទាត់ទី១ បង្ហាញពីឈ្មោះទេពម្នាក់ដែលកាលពីនៅមានជីវិតគឺជាព្រះរាជសិល្បករ។[៣] បន្ទាត់ទី២ បង្ហាញពីឈ្មោះទេពម្នាក់ ប្រហែលជាឈ្មោះដើមរបស់សិល្បករនោះ ***ស្រីចន្ទ្រស្វរៈ***។ បន្ទាត់ទី៣ បង្ហាញពីឈ្មោះទេពស្ត្រីម្នាក់ អាចជាភរិយារបស់សិល្បករខាងលើ ***ស្រីសាន្តីស្វរី*** បន្ទាត់ទី៤ បញ្ជាក់ថា នៅក្នុងបន្ទប់ជ្រុងអាគ្នេយ៍នេះជាទីកន្លែងរបស់សិល្បកររបស់ស្តេច ដែលមានគោរម្យងារជា ***វ្រះអំតេង*** និងអាចមេជាងគ្រប់គ្រងការស្ថាបនាប្រាសាទនេះ។

លើសពីនេះ តាមការស្រាវជ្រាវថ្មីរបស់ខ្ញុំ មានសិលាចារឹក២ផ្ទាំងផ្សេងទៀតនិយាយអំពីឈ្មោះទេពនៅក្នុងប្រាសាទនេះ ហើយពុំមានចុះបញ្ជី ឬបរិយាយក្នុងអត្ថបទរបស់លោកសឺដេសទេ។ ផ្ទាំងទី១ គឺបិតនៅលើស៊ុំទ្វារខាងត្បូងរបស់ទ្វារចន្លោះក្លោងទ្វារខាងកើតនិងក្លោងទ្វារអាគ្នេយ៍។ ប៉ុន្តែផ្ទាំងសិលាចារឹកនេះបានសឹករលប់ស្ទើរអស់ទៅហើយ គឺមិនអាចផ្តាមបាន និងអានបានទេ។ សិលាចារឹកផ្ទាំងទី២ គឺបិតនៅលើស៊ុំខាងកើតនៃទ្វារខាងជើងរបស់ប្រាង្គកណ្តាល។ សិលាចារឹកនេះជាផ្ទាំងសំខាន់ដែលបញ្ជាក់អំពីទេពដែលគេតម្កល់និងឧទ្ទិសដល់ប្រាង្គកណ្តាល ឬប្រាសាទនេះតែម្តង (រូបលេខ៤) មាន២បន្ទាត់ ដែលខាងលើបង្ហាញពីឈ្មោះទេព និងខាងក្រោមបញ្ជាក់អំពីបដិមាក្នុងប្រាង្គកណ្តាលនេះ។

(១) កម្រតេងជគតត្រីន្ទ្របេន្ទ្រេគ្វរី (kamraten jagat çrīnṛpendreçvarī)

(២) រូបកម្រតេងអញត្រីន្ទ្របេន្ទ្រ(ទេវី?) (rūp kaṃrateṅ añ çrīnṛpendradevī)

ក្នុងបន្ទាត់ទី១បង្ហាញអំពីទេពស្ត្រីម្នាក់ឈ្មោះ ***ស្រីនរបេន្ទ្រស្វរី*** ដែលជាទេពចម្បងនៅក្នុងប្រាង្គកណ្តាលនេះ។ បន្ទាត់ទីពីបង្ហាញថា នៅក្នុងបន្ទប់របស់ប្រាង្គកណ្តាលនេះមានតម្កល់បដិមាមួយអង្គតំណាងអោយទេពននេះ ហើយត្រូវបានគេប្រសិទ្ធិនាមថា ***ស្រីនរបេន្ទ្រទេវី***។

---

[៣] ពាក្យ សិល្បិ មានន័យថាសិល្បៈ ឬសិល្បករ ដែលក្នុងសម័យបុរាណគឺសំដៅលើក្រុមជាង ឬអ្នកសាងសង់ដូច វិស្វករដែរ។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ក្រៅពីសិលាចារិកទាំង៣ផ្ទាំងនេះ ក្នុងអត្ថបទនេះ ខ្ញុំចង់លើកមកបង្ហាញបន្ថែម អំពីអក្សរលើថ្មដែលបានរកឃើញនៅលើថ្មមួយចំនួនដែលគេបានយកមកស្ថាបនាប្រាសាទនេះ។ តើអក្សរថ្មជាអ្វី?[២]

តាមរយៈការស្វែងរក មានអក្សរ ឬសញ្ញាខ្វីនៅលើផ្ទៃមួយនៃដុំថ្មដែលគេមិនបានកាត់អោយស្មើ និងធ្វើអោយរលោង ដែលភាគច្រើនជាថ្មជញ្ជាំងខាងលើ ថ្មដំបូល និងថ្មកំពូល ផ្នែកខាងក្នុង។ ជាសរុប ខ្ញុំរកបានអក្សរនៅលើថ្មដែលអាចផ្តាម និងថតរូបបានចំនួន៥០។ លើសពីនេះ មានថ្មមួយចំនួនទៀតក៏មានអក្សរដែរ តែស្ថិតនៅលើចុងខាងលើនៃកំពូល (ផ្នែកខាងក្នុង) ដែលមិនអាចធ្វើការផ្តាមយកស្នាមអក្សរបាន។ ដោយសារថ្មទាំងនេះមិនទាន់មានលេខបញ្ជី និងដើម្បីងាយស្រួលបង្ហាញពីទីតាំងក្នុងប្លង់ ខ្ញុំបានដាក់លេខឱ្យថ្មទាំងនោះ ពីលេខ BP1ដល់ BP50 (BP=Banteay Prei)។ អក្សរទាំងនេះមានដូចជា៖ (រូបលេខ២៥ លេខ២៦ លេខ២៧ និងលេខ២៨)

BP1 ឧថ្មោផោ- - /uthmopho- - /

BP2 ឧខ្វំ /ukhvaṃ/

BP3 ឧ? /u?/

BP4 ខ្វំអហិក្វង (?) /khvaṃahikvaṅ/

BP5 ខ្វំវ្វវ្វទ្វ /khvaṃvvavvradva/

BP6 ត្វ - - (tva - -)

BP7 ឧ /u/

BP8 ឯកថ្វៃចគ /ekthvaicaga/

BP9 ឯក - /ek -/

BP10 គតេក (?) /gatek?/

BP11 ល /la/

BP12 ខ្វំ - - - -ល /khvaṃ - - - -la/

BP13 ឧទធ្យាទ (?) /udadhyād?/

[២] សូមអាន សុខ កែវ សុវណ្ណារ៉ា, ២០២០

BP14 (?) /?/

BP15 (?) /?/

BP16 ល្ទ (?) /lda?/

BP17 ឧថ /utha/

BP18 គល (?) /gala?/

BP19 ត - /ta -/

BP20 ជាសញ្ញា (?)

BP21 ឧ /u/

BP22 វិទ្យាវុប -ទោ /vidyāvupa – do/

BP23 តថ្មោផោលញទោទៅទៅ /tathmopholañdodaudau/

BP24 កវី /kavi/

BP25 ឧទ-វល វ្រៃត្នល - - -/uda – vala vraitnal - - -/

BP26 (?)

BP27 ជាសញ្ញា

BP28 - - - - -ក /- - - - - ka/

BP29 -ករវល /karavala/

BP30 - - - - - -(?)

BP31 ជាអក្សរ ឬសញ្ញា (?)

BP32 - - - - -(?)

BP33 ឧហ្មោ /uhmo/

BP34 ឧថ្មោក - /uthmoka -/

BP35 ខ្វំ (ញញ?) /khvaṃ (ñaña?)/

BP36 ឧគគ /ugaga/

BP37 ឧ /u/

BP38 ឯក - ថថាទោ /eka – thathādo/

BP39 ឯក -ទ្វេ - - - /eka – dve - - -/

BP40 ឧថ្មោ - គគ្វារ /uthmo – gagvār/

BP41 - ទ្យាន /- dyān/

BP42 - តធលធាគ /- tadhaladhāga/

BP43 កវិ - - - /kavi - - -/

BP44 ឧថ្មោ - ជល /uthmo - jala/

BP45 វិទ្យា - - - /vidyā - - -/

BP46 ឧវិទ្យាវិ - /uvidyāvi -/

BP47 ឧ (?) /u?/

BP48 ឧថ្មោ - /uthmo -/

BP49 ឯក /eka/

BP50 ឧថ្មោផោ - - /uthmopho - -/

តួអក្សរទាំងនេះត្រូវបានគេដាប់យ៉ាងជ្រៅ ហើយធំៗ មិនដូចផ្ទាំងសិលាចារឹក ដូចនេះហើយធ្វើឱ្យពិបាកក្នុងការផ្ដាម និងយល់អំពីតួអក្សរអស់នេះបានទាំងស្រុងនោះទេ។ ភាគច្រើននៃតួអក្សរទាំងនេះគឺចង់បង្ហាញពីថ្ម (ឧថ្មោ ឬថ្មោ) អាចជាស្លាកនាមរបស់ការដ្ឋានយកថ្ម ឬក៏សិប្បកម្មកាត់ថ្ម។ ដោយសារភាពមិនច្បាស់លាស់នេះ ខ្ញុំពិបាកក្នុងការអាន ឬកត់សម្គាល់តួអក្សរនីមួយៗថាជាព្យញ្ជនៈអ្វីអោយប្រាកដមួយរយភាគរយទេ។ នេះជាការបង្ហាញត្រួសៗជាបឋម មិនទាន់សម្រេចយកជាការណ៍ត្រឹមត្រូវទេ ពេលគឺត្រូវសិក្សា ពិនិត្យអោយបានម៉ត់ចត់បន្ថែមទៀត។ អត្ថបទនេះទុកជាព័តមានសម្រាប់អ្នកសិក្សាសិលាចារឹកបុរាណ ធ្វើការស្រាវជ្រាវបន្ត។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណ៉ា

# ឯកសារយោង

សុខ កែវ សុវណ្ណារ៉ា
២០២០. *អក្សរលើថ្មរបស់សំណង់កណ្ដាលស្រះស្រង់*, លេខ២២, សៀមរាប

E. Lunet de Lajonquière
(1911), *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris.

George Cœdès
1951. *Banteay Prei*, Befeo, p.116, Tome XLIV, Paris.




រូបលេខ១៖ ផែនទីបង្ហាញទីតាំងប្រាសាទបន្ទាយប្រី ▲



រូបលេខ២៖ ប្លង់ប្រាសាទបន្ទាយប្រី (ប្រភពអង្គការអេប្យាក)



រូបលេខ៣៖ ផ្ទាំងសិលាចារឹកលើសុំទ្វារខាងលិច បន្ទប់ជ្រុងអាគ្នេយ៍



រូបលេខ៤៖ ផ្ទាំងសិលាចារឹកលើទ្វារខាងជើង ប្រាង្គកណ្តាល

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ៥៖ អក្សរលើថ្ម




រូបលេខ៦៖ អក្សរលើថ្ម




រូបលេខ២៧៖ អក្សរលើថ្ម




រូបលេខ២៨៖ អក្សរលើថ្ម

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉